ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ


រដ្ឋសភា

គណៈកម្មការ ផែនការ វិនិយោគ កសិកម្ម
អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក

លេខ...............................រ.ស.គ៣


# សូមគោរពជូន
# សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា

## កម្មវត្ថុ៖ របាយការណ៍ស្តីពី
## បេសកកម្មរបស់គណៈកម្មការផែនការវិនិយោគកសិកម្ម
## អភិវឌ្ឍន៍ជនបទបរិស្ថាននិងធនធានទឹកនៃរដ្ឋសភានៅខេត្តស្ទឹងត្រែង
## កាលពីថ្ងៃទី២៦ដល់២៩ខែមីនា ឆ្នាំ២០១៥

កាលពីថ្ងៃទី២៦ដល់២៩ខែមីនាឆ្នាំ២០១៥ដោយមានការអនុញ្ញាតពី **សម្តេចប្រធានរដ្ឋសភា** គណៈប្រតិភូគណៈកម្មការផែនការ វិនិយោគកសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹកនៃរដ្ឋសភាដឹកនាំដោយខ្ញុំបាទ ប៉ុល ហំម បានចុះបំពេញបេសកកម្មនៅក្នុងខេត្តស្ទឹងត្រែងដើម្បីសិក្សាស្វែងយល់ពីតំបន់ទំនប់វារីអគ្គិសនីសេសានក្រោម២និងទំនប់វារីអគ្គិសនីដនសាហុងកាលពីថ្ងៃទី២៦-២៩ខែមីនា ឆ្នាំ២០១៥ របស់គណៈកម្មការទី៣ នៃរដ្ឋសភា ដូចខាងក្រោម៖

### I. ជំនួបជាមួយគណៈអភិបាលខេត្តស្ទឹងត្រែង៖

នៅក្នុងដំណើរបំពេញបេសកម្ម គណៈកម្មការទី៣ នៃរដ្ឋសភាបានជួបប្រជុំការងារជាមួយគណៈអភិបាលខេត្តស្ទឹងត្រែង ដើម្បីស្វែងយល់ និងស្តាប់របាយការណ៍អំពីស្ថានភាពការងាររបស់ខេត្ត ដែលបានអនុវត្តកន្លងមក ជាពិសេសទាក់ទងទៅនឹងគោលបំណងរបស់គណៈកម្មការ ។ ឯកឧត្តម *កុលសំអុល* អភិបាលខេត្តបានស្វាគម និងជម្រាបជូន គណៈប្រតិភូអំពីស្ថានភាពរួមរបស់ខេត្តស្ទឹងត្រែង បញ្ហាប្រឈម ក៏ដូចជាសំណូមពរដល់ គណៈកម្មការទី៣លើបញ្ហាមួយចំនួនដូចតទៅ៖

1) បញ្ហាទំនប់វារីអគ្គិសនីដនសាហុង៖

ប្រសិនបើទំបន់វារីអគ្គិសនីដនសាហុងនេះដំណើការវានឹងធ្វើឲ្យប៉ះពាល់៖

- ធនធានជលផលដូចជាបាត់បងពូជត្រីសត្វផ្សោត



វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (៨៥៥-២៣) ២១៥ ៩៣១ ទូរសារ : (៨៥៥-២៣) ២១៥ ៩៣១

- បាត់បង់ជំរកត្រីពងពីព្រោះតំបន់នេះជាអន្លង់ត្រីពងដើម្បីចែកចាយទូទាំងប្រទេសរហូតដល់ទន្លេសាបទៀតផង
- ទន្លេមេគង្គជាឪពុកម្តាយទន្លេទាំងអស់នៅក្នុងកម្ពុជាជាហេតុធ្វើឲ្យប៉ះពាល់ដល់សេដ្ឋកិច្ចសង្គមនិងជីវភាពប្រជាពលរដ្ឋជាពិសេសប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សន្តិសុខស្បៀង
- បាត់បង់ជីវចំរុះនិងបាត់បង់ប្រព័ន្ធអេកូឡូស៊ីកត្តានេះនាំឲ្យប៉ះពាល់ដល់វិស័យទេសចរណ៍
- អាចធ្វើឲ្យជនលិចឬខ្វះទឹកធ្វើស្រែ

ឯកឧត្តម *កុលសំអុល* ក៏សំណូមពរដល់គណៈកម្មការទី៣មេត្តាជួយអន្តរាគមន៍ទៅតាមសមត្ថកិច្ច និងភារកិច្ចរបស់គណៈកម្មការជំនាញរដ្ឋសភា ក្នុងអន្តរាគមន៍ដល់ប្រទេសឡាវកុំឲ្យសង់ទំនប់វារីអគ្គិសនីដនសាហុង។

នៅរសៀលថ្ងៃដដែលគណៈកម្មការបានចុះទៅជួបជាមួយប្រជាពលរដ្ឋក៏ដូចជាប្រជាសហគមន៍ ដែលទទួលរងផលប៉ះពាល់ និងតំណាងអង្គការសង្គមស៊ីវិល ដែលពាក់ព័ន្ធនឹងបរិស្ថាន ធនធានធម្មជាតិ នៃទំនបន់វារីអគ្គិសនីដនសាហុង នៅក្នុងភូមិអន្លង់ស្វាយ ឃុំព្រះរំកិល ខេត្តស្ទឹងត្រែងក្រោយមកគណៈកម្មការទទួលមតិយោបល់ស្រដៀងគ្នាអំពីក្តីបារម្ភ និងមិនចង់ឲ្យមានការសាងសងទំបន់វារីអគ្គិសនីដនសាហុងនេះទេ ពីព្រោះវានឹងធ្វើឲ្យប៉ះពាល់ដល់ប្រជាពលរដ្ឋដែលអាស្រ័យផលលើដងទន្លេនេះ ជាពិសេសជីវភាពរបស់ប្រជាពលរដ្ឋ។ ហើយពួកគេបានសំណូមពរដល់គណៈកម្មការទី៣ ជួយអន្តរាគមន៍តាមយន្តការរដ្ឋសភាក្នុងការទប់ស្កាត់កុំឲ្យមានការសាងសង់ទំនប់វារីអគ្គិសនីដនសាហុងនេះ។

គណៈកម្មការទី៣ នៃរដ្ឋសភា ក៏សំណូមពរដល់ប្រជាពលរដ្ឋនិងសហគមន៍វិញជួយការពារធនធានធម្មជាតិ កុំនេសាទត្រីដោយប្រើឧបករណ៍ហាមឃាត់ ដូចជា គ្រឿងឆក់ ដាក់គ្រាប់បែកជាដើម ។

2) បញ្ហាទំនប់វារីអគ្គិសនីសេសានក្រោម២៖

- គណៈកម្មការដោះស្រាយផលប៉ះពាល់ដល់ប្រជាពលរដ្ឋបាន៧០% ហើយ ប៉ុន្តែនៅសេសសល់ប្រមាណ៣០%ទៀតកំពុងតែអនុវត្ត។ បញ្ហាសេសសល់នេះគឺប្រជាពលរដ្ឋទាមទារតំឡើងផ្ទៃដីលំនៅដ្ឋាន ពី២០x៥០ម៉ែត្រ ទៅ៥០x១០០ម៉ែត្រ វិញ និងបញ្ហាផ្ទះដូនតាដែលត្រូវចេញថ្លៃគាស់ និងថ្លៃបញ្ចុះ ក្នុងតម្លៃ១៥០០ដុល្លារ ចំណែកសំណង់ផ្សេងៗដែលក្រុមហ៊ុនបានលើកនោះគឺពួកគាត់ព្រមទទួលយកទាំងអស់។
- បញ្ហាប្រឈមមួយទៀតគឺមានអង្គការទន្លេបី ដែលមិនទាន់បានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃបាននឹងកំពុងរារាំងមិនឲ្យប្រជាពលរដ្ឋចាកចេញពីកន្លែង ដែលរងផលប៉ះពាល់។

នៅក្នុងជំនួបនោះក៏មានការលើកឡើងនូវសំណួររបស់សមាជិកគណៈកម្មការទី៣ ដូចជា៖

- ✓ តើមានការកាប់បំផ្លាញព្រៃឈើនៅក្រៅតំបន់អាងទំនប់វារីអគ្គិសនីដឹកចូលមកក្នុងតំបន់បាតអាងដែរឬទេ ? តើការដោះស្រាយផលប៉ះពាល់សមស្របឬនៅ ទើបបានជាមានប្រជាពលរដ្ឋនៅតែតវ៉ា ?
- ✓ តើមានអង្គការប៉ុន្មានទៀតក្រៅពីអង្គការទន្លេបី ដែលកំពុងរារាំង និងថាតើការទាមទារនេះដើម្បីអ្វី ?
- ✓ ឈើដែលកាប់ដើម្បីសំអាតបាតអាងតើមានបានចុះក្នុងបញ្ជីសារពើភ័ណ្ឌរបស់រដ្ឋដែរឬទេហើយបានបង់ពន្ធជូនរដ្ឋរួចហើយឬនៅ ?

បន្ទាប់ពីស្តាប់សំណួររួចមក ឯកឧត្តម *កុលសំអុល* ក៏បានឆ្លើយបំភ្លឺវិញថាគ្មានករណីកាប់ឈើនៅតំបន់ក្រៅអាងមកចូលក្នុងអាងទេ ពីព្រោះផ្លូវឆ្ងាយ ណាស់និងពិបាកយកចេញ ។ ម្យ៉ាងទៀតឈើនៅតំបន់នោះគ្មានឈើល្អសម្រាប់នាំចេញទេ ប៉ុន្តែឈើក្រញូងនៅតែមានដឹកឆ្លងកាត់ខេត្តស្ទឹងត្រែង ឈើក្រញូងនេះគឺកាប់ចេញពីឡាវនិងថៃ ហើយគ្រាន់តែឆ្លងកាត់ខេត្តតែប៉ុណ្ណោះ។ ហើយបញ្ហាកាប់ឈើទន្រ្ទានយកដីនៅតែមានបញ្ហានេះ ខេត្តពិបាកក្នុងការទប់ស្កាត់ ពីព្រោះច្បាប់ព្រៃឈើមាត្រា៧៦ បានចែងថាជាសមត្ថកិច្ចរបស់ក្រសួងកសិកម្ម។ មានការដុតចោលឈើនៅតំបន់ស្តារអាងទំនប់វារីអគ្គិសនីព្រោះជាឈើគ្មានតម្លៃហើយពុកអស់។

## II. **ជំនួបជាមួយតំណាងអង្គការសង្គមស៊ីវិលៈ**

នៅថ្ងៃទី២៨ខែមីនាឆ្នាំ២០១៥ វេលាម៉ោង៨:០០ព្រឹក គណៈកម្មការបានអនុញ្ញាតឲ្យតំណាងអង្គការ សង្គមស៊ីវិលធ្វើបទបង្ហាញនិងក្តីបារម្ភអំពីការសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ ហើយតំណាងអង្គការទន្លេបីបានធ្វើបទបង្ហាញជូនគណៈកម្មការអំពីការប៉ះពាល់ដូចតទៅៈ

- ❖ ប៉ះពាល់លើធនធានបរិស្ថានៈ

  ១.ផ្ទៃដីបាតអាងត្រូវលិចទឹកជា៣៦០០០ហិកតា

  ២.ប្រែប្រួលលំហូរទឹកនិងខូចគុណភាពទឹក

  ៣.ផ្ទៃដីព្រៃឈើរាប់ម៉ឺនហិកតាត្រូវកាប់បំផ្លាញ

  ៤.២៥% នៃដីកសិកម្មស្រុកសេសាននឹងត្រូវលិចលង់

  ៥.បាត់បង់ជំរកត្រីជីវចំរុះនិងប្រភេទត្រីកម្រជិតផុតពូជ

  ៦.ប៉ះពាល់ដល់ទិន្នផលត្រី

  ៧.ត្រីមិនអាចឆ្លងកាត់និងរកទីពងបាន

  ៨.បាត់បង់នូវរុក្ខជាតិព្រៃលិចទឹកនិងប្រភេទរុក្ខជាតិដុះលើថ្មប៉ប្រះទឹក
- ❖ ផលប៉ះពាល់លើសង្គមនិងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋៈ

  ១.បាត់បង់ដីឯកជន

  ២.បាត់បង់តំបន់ចិញ្ចឹមសត្វ (ឧ. ព្រៃឈើវាលស្មៅ )

  ៣.បាត់បងអនុផលព្រៃឈើនិងទេសចរណ៍

៤.សន្តិសុខស្បៀង

៥.កើនឡើងនូវរោគនិងជំងឺផ្លូវចិត្តបណ្តាលពីភាពមិនសប្បាយចិត្តនឹងគម្រោង

៦.ប្រពៃណីទំនៀមទំលាប់ផ្លូវដូនតា

សំណូមពរសូមឲ្យផ្អាកការសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២បណ្តោះអាសន្ន រងចាំឲ្យក្រុមហ៊ុនដោះស្រាយផលប៉ះពាល់ជូនប្រជាពលរដ្ឋឲ្យរួចរាល់សិន ។

ជាចុងក្រោយអង្គការបណ្តាញការពារទន្លេសេសានស្រែពកសេកុង (ទន្លេបី) បានបញ្ជាក់អះអាងថាអង្គការរបស់ខ្លួនបានចុះបញ្ជីនៅក្រសួងមហាផ្ទៃត្រឹមត្រូវតាមច្បាប់ខុសពីអ្វីដែលអាជ្ញាធរខេត្តបានចោទថាអង្គការនេះមិនមានលក្ខណៈផ្លូវច្បាប់ត្រឹមត្រូវនោះទេ។

- ជំនួបជាមួយប្រជាពលរដ្ឋ និងសហគមន៍ដែលប៉ះពាល់ដោយទំនប់វារីអគ្គសនីសេសានក្រោម២៖
    - យោបល់របស់មេឃុំស្រែគរ ស្រុកសេសានសុំឲ្យអាជ្ញាធរដែនដី កុំរាំងដល់សកម្មភាពអង្គការមួយចំនួនព្រោះពួកគាត់ចុះមកបណ្តុះបណ្តាលឲ្យអ្នកភូមិបានយល់ពីច្បាប់ ព័ត៌មាន និងចំណេះដឹងមួយចំនួន ដែលពួកគាត់ពុំដែលដឹងៗ។
    - ប្រជាពលរដ្ឋពលរដ្ឋនៅភូមិស្រែគរ (ខ្មែរ-ឡាវ) ខ្លះព្រមទទួលយកសំណងតាមដែលក្រុមហ៊ុនបានបញ្ជាក់ប្រាប់គឺ ៥០ម៉ែត្រ×១០០ម៉ែត្រ ។
    - ជនជាតិដើមភាគច្រើនពុំទទួលយកសំណងទេ គឺពួកគាត់សុខចិត្តស្លាប់នៅលើភូមិកំណើតរបស់ពួកគាត់ ។

## III. សរុបមតយោបល់របស់គណៈកម្មការទី៣ ៖

➢ ទំនប់វារីអគ្គិសនីដនសាហុង ៖

បន្ទាប់ពីគណៈកម្មការទី៣ នៃរដ្ឋសភា បានចុះពិនិត្យជាក់ស្តែងរួចមក ខ្ញុំបាទយល់ឃើញថាទំនប់វារីអគ្គិសនីដងសាហុង ទាំងអាជ្ញាធរមូលដ្ឋាន ទាំងប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល មានស្មារតីនិងគំនិតដូចគ្នា គឺមិនចង់ឲ្យភាគីឡាវសាងសង់ទំនប់វារីអគ្គិសនីនេះឡើយ។ គណៈកម្មការទី៣ នៃរដ្ឋសភា គាំទ្រនូវមតិនេះ ។

➢ ទំនប់វារីអគ្គិសនីសេសានក្រោម២ ៖

ចំណែករឿងទំបន់វារីអគ្គិសនីសេសានក្រោម២គណៈកម្មការទី៣ស្នើសុំឲ្យគណៈកម្មការដោះស្រាយផលប៉ះពាល់ ដែលមាន ឯកឧត្តមអភិបាលខេត្ត ជាប្រធាន ក៏ដូចជាតំណាងក្រុមហ៊ុន ធ្វើយ៉ាងណាក្នុងការផ្តល់សំណងដល់ប្រជាពលរដ្ឋឲ្យបានសមរម្យ ដើម្បីឲ្យពួកគាត់ស្ងប់ចិត្តជៀសវាងទំនាស់ផ្សេងៗ ដែលនាំឲ្យបង្អាក់ដល់ការកសាងទំនប់វារីអគ្គិសនី ។

- បើប្រជាពលរដ្ឋយល់ព្រមទទួលសំណងហើយ គណៈកម្មការដោះស្រាយផលប៉ះពាល់ គួរដោះស្រាយដូចបានបញ្ជាក់ប្រាប់ប្រជាពលរដ្ឋមុនពេលអនុវត្តគម្រោង គឺដីលំនៅដ្ឋាន៥០ម៉ែត្រ×១០០ម៉ែត្រ មានទំហំផ្ទះ៨០ ម៉ែត្រការ៉េ និងដីបង្កបង្កើនផល ៥ហិកតា ។

- សំណើបន្ថែមរបស់ប្រជាពលរដ្ឋស្នើសុំថវិកាសំរាប់ធ្វើបុណ្យផ្ទះជូនតា ថ្លៃគាស់សព និងបញ្ចុះសពគឺ ១៥០០-២០០០$ ។
- ទាំងអភិបាលខេត្ត ទាំងអង្គការសង្គមស៊ីវិល និងទាំងប្រជាពលរដ្ឋមិនបាន បញ្ជាក់ថាមិនឲ្យរាជរដ្ឋាភិបាលសាងសង់ទំនប់វារីអគ្គិសនីទេ គ្រាន់តែសូមផ្អាក ដើម្បីដោះស្រាយផលប៉ះពាល់ឲ្យពួកគាត់មុនសិន ។
- មានរបាយការណ៍មិនដូចគ្នារវាងអភិបាលខេត្តស្ទឹងត្រែងថាគ្មានការកាប់ព្រៃឈើពីកន្លែងក្រៅអាងស្តុកទឹកទេ ឯប្រជាពលរដ្ឋ និងសង្គមស៊ីវិលថាមានការកាប់ទន្ទ្រានយកឈើប្រណិតជារៀងរាល់ថ្ងៃ ឯការកាប់នេះគឺចាប់តាំងពីឆ្នាំ២០១១ មកម្លេះ ហើយបណ្តាលឲ្យខូចខាតផ្លូវ និងស្ពានមួយចំនួនថែមទៀតផង ។

សេចក្តីដូចបានជម្រាបជូននៅក្នុងខ្លឹមសារខាងលើ សូម **សម្តេចប្រធាន** មេត្តាជ្រាបជារបាយណ៍ដ៏ខ្ពង់ខ្ពស់ ។

សូម **សម្តេចប្រធាន**មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ.ថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១៥

**ប្រធាគណៈកម្មការទី៣ នៃរដ្ឋសភា**

ប៉ុល ហំម

**ចម្លងជូន**

-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គនាយកដ្ឋានសេវា និងបច្ចេកទេស

" ដើម្បីជូនជ្រាប "

-ឯកសារកាលប្បវត្តិ